ព្រះរាជាណាចក្រកម្ពុជា

KINGDOM OF CAMBODIA

ជាតិ សាសនា ព្រះមហាក្សត្រ

Nation Religion King

0 886 538 360

អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ

ចូល

លេខ 1214

ថ្ងៃទី 30 ខែ 7 ឆ្នាំ២០១៣

ម៉ោង 09:50 នាទី

## ពាក្យបណ្តឹង

## Complaint

ខ្ញុំបាទឈ្មោះ Etienne Chenevier ជាតំណាងអោយក្រុមហ៊ុន City Star ដែលមានស្នាក់ការនៅផ្ទះលេខ ៥៥ ផ្លូវលេខ ១៧៨ រាជធានីភ្នំពេញ។ តំណាងដោយលោក មេធាវី គង់ រ៉ាឌី មានការិយាល័យនៅផ្ទះលេខ ៦០៦D ផ្លូវលេខ ៣៥៨ សង្កាត់ច្បារ អំពៅ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ទូរស័ព្ទលេខ០១២ ៩២៥៩៩០។

I am **Etienne Chenevier**, the representative of City Star, having its office at #55, street 178, Phnom Penh, Represented by Atty. KONG RADY, located at # 606D, street 358, Sangkat Chbar Ampov 2, Khan Mean Chey, Phnom Penh, Tel: 012 925990.

សូមគោរពចូលមក

To

ឯកឧត្តមព្រះរាជអាជ្ញាអមសាលាដំបូងរាជធានីភ្នំពេញ

The Prosecutor Attached to the Phnom Penh Court of First Instance

**កម្មវត្ថុ៖** ប្តឹងឈ្មោះ Mr. Rupert Winchester ជនជាតិអង់គ្លេស ជាអតីតអ្នកនិពន្ធជាន់ខ្ពស់ នៃកាសែតភ្នំពេញប៉ុស្តិ៍ពីបទបរិហាកេរ្តិ៍ ប្រព្រឹត្តកាលពីថ្ងៃទី ០៤ ខែមិថុនា ឆ្នាំ ២០១៣។

**Subject:** Suing Mr. Rupert Winchester, English, Former Senior Editor at Phnom Penh Post, of defamation committed on June 4, 2013.

**យោង៖** មាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌ

**Ref:** Article 305 of the Criminal Code

តបតាមកម្មវត្ថុខាងលើ ខ្ញុំសូមជំរាបជូនឯកឧត្តមព្រះរាជអាជ្ញាមេត្តាជ្រាបថា កាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ ២០១៣ លោក Rupert Winchester បានចុះផ្សាយក្នុងទំព័រឯកជនតាមអ៊ិនធឺណែតរបស់គាត់ ដែលមានចំណងជើងថា "The Mighty Penh" នូវអត្ថបទមួយដែលមានចំណងជើងថា «ខ្ញុំត្រូវគេបំផ្លាញចោល»។ ក្នុងនោះមានខ្លឹមសារបរិហាកេរ្តិ៍ខ្ញុំបាទ និងក្រុមហ៊ុន City Star។

As to the subject mentioned above, I would like to inform the Prosecutor that on June 4, 2013 Mr. Rupert Winchester published on his personal blog entitled **"The Mighty Penh"** an article entitled **"I Get Knocked Down"**. Defamatory remarks were made by about me and about our company City Star.

ទីមួយ អត្ថបទនេះនិយាយអំពីផ្ទះមួយ ដែលបានកសាងឡើងជាភូមិគ្រឹះរាជវង្ស ក្នុងចន្លោះឆ្នាំ ១៩០០ ទៅឆ្នាំ ១៩១០ មានទីតាំងនៅផ្លូវលេខ ១៧៨ ទល់មុខសារមន្ទីរជាតិ ហើយអត្ថបទនេះនិយាយច្បាស់ថា ក្រុមហ៊ុន City Star នឹងកំទេចផ្ទះនេះចោល ដើម្បីសង់អគារខុនដូ ៧ជាន់ជំនួសវិញ។ ដែលនេះគឺជាការប្រឌិតទាំងស្រុង។ តាមពិត ក្រុមហ៊ុន City Star មិនដែលមានបំណងកំទេចផ្ទះនេះទេ ផ្ទុយទៅវិញក្រុមហ៊ុនបានបញ្ជាក់យ៉ាងច្បាស់នៅក្នុងផែនការរបស់ខ្លួនថា នឹងមិនកំទេចផ្ទះនេះចោលនោះទេ។

Chen

First, the article is about a house originally built as a royal villa between 1900-1910, on Street 178, across from the National Museum, and it implies explicitly that City Star is going to knock down the house to build a seven story condominium on the site instead, which is complete fabrication. City Star had no intention to knock down the building in fact it was clearly stated in the plans with the city that it was not going to be knocked down.

ទីពីរ កាន់តែធ្ងន់ធ្ងរថែមទៀត គឺបន្ទាប់មកអ្នកយកពត៌មានបានទូរស័ព្ទមកខ្ញុំ ហើយខ្ញុំបានព្យាយាមពន្យល់គាត់ ថាហេតុអ្វីយើងចង់វាយកម្ទេចអគារផ្ទាល់ខ្លួនរបស់យើង ? ហើយខ្ញុំក៏និយាយផងដែរថា ប្រសិនបើអ្នកចុះផ្សាយ ខ្ញុំនឹងប្តឹងអ្នក"។ នៅក្នុងគេហទំព័រនេះ លោក Rupert Winchester បាននិយាយសំដៅមកខ្ញុំ ហើយនិយាយថា «ខ្ញុំនិយាយថាអ្នកនឹង (កំទេចវាចោល)»។ កំទេចខ្លួនឯងទៅអញ្ចឹង បើសិនអ្នកគិតថាការប្តឹងផ្តល់គឺជារឿងឆ្លាតវៃ មនុស្សឃោសនាបោកប្រាស់ថោកទាប។ ក្រោយមកលោក Rupert Winchester បានដកពាក្យនេះចេញនៅថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៣ ដោយសារពេលនោះ គាត់នៅធ្វើការជាមួយកាសែតភ្នំពេញប៉ុស្ដ៍ ហើយគាត់បានចុះផ្សាយអត្ថបទស្ទើរតែដូចគ្នានេះ លើកាសែតភ្នំពេញប៉ុស្ដ៍ ដែលអត្ថបទនេះត្រូវបានកែតម្រូវដោយភ្នំពេញប៉ុស្ដ៍រួចហើយ។

Secondly, even more egregious after the reporter called me and I tried to tell him and I said "Why would we knock down our own building and I also said if he prints that I will I will sue him" In the blog Rupert Winchester refers to me and states in the same paragraph "Well I say you will (knock it down). Knock yourself out, suing -wise, you cheap aggressive huckster". Rupert Winchester removed this language by the June 7, 2013 because he was at that time a reporter for the Phnom Penh Post (Post) and he wrote nearly the same article for the Post and that article was subsequently retracted by the Post.

ការវាយប្រហារជាបុគ្គលមកលើរូបខ្ញុំ គឺគ្មានហេតុផលទាល់តែសោះ ហើយការវាយប្រហារនេះបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា និងអានដោយមនុស្សទូទាំងពិភពលោក។ ពត៌មាននៅលើគេហទំព័ររបស់គាត់មិនត្រឹមត្រូវទេ ហើយបានបង្កការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ក្រុមហ៊ុន City Star ដែលជាម្ចាស់ និងជាអភិវឌ្ឍន៍ទ្រព្យនេះ ក៏ដូចជាកិត្តិយសរបស់ខ្ញុំផងដែរ។ គោលបំណងរួមនៃអត្ថបទរបស់គាត់គឺដើម្បីបរិហារកេរ្តិ៍របខ្ញុំ និងក្រុមហ៊ុន City Star ដែលអំពើនេះ ត្រូវផ្តន្ទាទោសតាមមាត្រា ៣០៥ នៃក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។

The personal attack on me was unfounded and this was published in Cambodia and read around the world. The information on his blog was not true and has seriously damaged City Star who is the owner and developer of the property and my reputation. The entire intent of his blog was to defame me and City Star which is punishable under article 305 of the Criminal Code of Cambodia.

អាស្រ័យហេតុនេះ សូមលោកព្រះរាជអាជ្ញាមេត្តាចោទប្រកាន់ឈ្មោះ Rupert Winchester តាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដោយក្តីអនុគ្រោះ។

Therefore, I would like the Prosecutor to prosecute Mr. Rupert Winchester according to the law of Cambodia.

AVOCAT
ATTORNEY
AT LAW
KINGDOM OF CAMBODIA

មេធាវី.គង់_រ៉ាវី

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី .......... ខែកក្កដា ឆ្នាំ ២០១៣

Made in Phnom Penh on 27 July 2013

Etienne Chenevier